# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧២...អនក្រ..បក

# អនុក្រឹត្យ

## ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតចំការកៅស៊ូមេមត់ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ-បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍ព្រះរាជក្រមស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្ទង់ការគណនីនៃសហគ្រាសសាធារណៈ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

### មាត្រា ១.-

មាត្រា២៣ នៃអនុក្រឹត្យលេខ ១៣ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូមេមត់ជាគ្រឹះស្ថានសាធារណៈមាន លក្ខណៈសេដ្ឋកិច្ច ត្រូវបានកែសំរួលដូចខាងក្រោម :

**មាត្រា ២៣ ថ្មី :**

រៀងរាល់ឆ្នាំ ក្រោយពីធ្វើការទូទាត់ស្របតាមវិធានគណនេយ្យ ប្រាក់ចំណេញនៅសល់ត្រូវបង់ចូលថវិកាជាតិទាំងអស់ ឬមួយផ្នែក ឬរដ្ឋអាចរក្សាទុកទាំងអស់អោយសហគ្រាស ក្នុងករណីដែលរដ្ឋពិនិត្យឃើញថាត្រូវធ្វើការអភិវឌ្ឍជាចាំបាច់ ។

### មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

### មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ